**ព្រឹទ្ធសភា**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**គោរពជូន**
**សម្តេចពិជ័យសេនា ទៀ បាញ់**
**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ និងលោកជំទាវ**

សម្តេចពិជ័យសេនា និងលោកជំទាវ ជាទីគោរពស្រឡាញ់រាប់អាន

ក្នុងឱកាសដ៏មង្គលសួស្តី ប្រកបដោយមនោសញ្ចេតនាសោមនស្សរីករាយ ឆ្លងឆ្នាំចាស់ឈានចូលឆ្នាំថ្មី ឆ្នាំសកល គ្រិស្តសករាជ២០២០ ដែលនឹងឈានមកដល់ក្នុងពេលខាងមុខនេះ ក្នុងនាមសមាជិក សមាជិកា ព្រឹទ្ធសភា និងក្នុងនាមខ្លួនខ្ញុំផ្ទាល់ ខ្ញុំសូមចូលរួមសម្តែងនូវអំណរសាទរយ៉ាងកក់ក្តៅ និងសូមជូនពរជ័យ សិរីមង្គល វិបុលសុខដ៏មហាប្រសើរបំផុតជូន **សម្តេចពិជ័យសេនា និងលោកជំទាវ** ព្រមទាំងបុត្រា បុត្រី ចៅប្រុស ចៅស្រីជាទីស្រឡាញ់ទាំងអស់ សូមបានប្រកបដោយពុទ្ធពរទាំងបួនប្រការ គឺអាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

ខ្ញុំសូមគោរពវាយតម្លៃខ្ពស់បំផុតចំពោះទឹកចិត្តស្នេហាជាតិ ស្នេហាប្រជាជនដ៏ស្មោះស្ម័គ្ររបស់ **សម្តេចពិជ័យសេនា** ដែលច្រើនឆ្នាំកន្លងមក ក៏ដូចឆ្នាំ២០១៩ សម្តេចបានពុះពារគ្រប់ឧបសគ្គបំពេញបេសកកម្មជាប្រវត្តិសាស្ត្រជូនជាតិមាតុភូមិ និងប្រជាជន តាមរយៈការពង្រឹងការពារអធិបតេយ្យភាព និងបូរណភាពទឹកដី ការកែទម្រង់ក្នុងវិស័យការពារជាតិ ជាពិសេសការពង្រឹងការពារសន្តិសុខនៅតាមព្រំដែន ស្របតាមគោលនយោបាយការពារជាតិរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា។

សូម **សម្តេចពិជ័យសេនា និងលោកជំទាវ** ទទួលនូវការគោរពរាប់អានដ៏ស្មោះស្ម័គ្របំផុតអំពីយើងខ្ញុំទាំងអស់គ្នា។

ថ្ងៃ សុក្រ ២ កើត ខែ បុស្ស ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦៣
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១៩
**ប្រធានព្រឹទ្ធសភា**

**សម្តេចវិបុលសេនាភក្តី សាយ ឈុំ**

វិមានរដ្ឋចំការមន មហាវិថីព្រះនរោត្តម រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទលេខ: (៨៥៥ ២៣) ២១១ ៤៤១, ២១១ ៤៤២, ២១១ ៤៤៣ ទូរសារលេខ: (៨៥៥ ២៣) ២១១ ៤៤៦, Email: oumsarith.sgsenate@gmail.com